ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១៧,៨៧ ហិកតា នៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ចេញពីដីព្រៃសហគមន៍ស្រុកត្រាំកក់ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៦២ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ០៧៦ សណ ចុះថ្ងៃទី០៣ខែ ឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ១៧,៨៧ ហិកតា ចេញពីដីព្រៃសហគមន៍ស្រុកត្រាំកក់ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មទំហំ ១៦,៥១ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ១,៣៦ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅ ភូមិត្រពាំងខ្នារ ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៦២ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិត្រពាំងខ្នារ ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*